ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៧។

ADB ASIAN DEVELOPMENT BANK

# ប្រទេសកម្ពុជា៖ គម្រោងថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា

| | |
|---|---|
| **ឈ្មោះគម្រោង** | **គម្រោងថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា** |
| **លេខគម្រោង** | 50248-001 |
| **អ្នកខ្ចីកម្ចី/ក្រុមហ៊ុន** | Sunseap Asset (Cambodia) Co. Ltd. |
| **ប្រទេស** | កម្ពុជា |
| **ទីតាំង** | |
| **លេខអនុម័ត** | |
| **ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ** | ត្រូវបានស្នើឡើង |

| | |
|---|---|
| របៀបវារៈយុទ្ធសាស្ត្រ | កំណើនដែលធានានិរន្តរភាពបរិស្ថាន<br>កំណើនសេដ្ឋកិច្ចបរិយាប័ន្ន |
| កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ | ភាពជាដៃគូ<br>ការអភិវឌ្ឍវិស័យឯកជន |
| វិស័យ/អនុវិស័យ | ថាមពល - ការបង្កើតថាមពលកកើតឡើងវិញ - ពន្លឺព្រះអាទិត្យ |
| សមធម៌យេនឌ័រ និងការបញ្ជ្រាបយេនឌ័រ | ពុំមានសមាសភាពយេនឌ័រឡើយ |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | នាយកដ្ឋានប្រតិបត្តិការវិស័យឯកជន |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | ផ្នែកហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធទី ២ |
| មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | Hashizume, Shuji |
| អ្នកឧបត្ថម្ភគម្រោង | |

| | |
|---|---|
| ការពណ៌នា | ក្នុងគម្រោងនេះ នឹងមានការសាងសង់ និងដំណើរការគម្រោងថាមពលពន្លឺព្រះអាទិត្យសម្រាប់អតិថិជនប្រើប្រាស់លើកទីមួយ ក្នុងប្រទេសកម្ពុជា ជាមួយនឹងសមត្ថភាព ១០ មេកាវ៉ាត់។ គម្រោងនេះមានទីតាំងក្នុងក្រុងបាវិត ខេត្តស្វាយរៀង ជិតព្រំដែនជាមួយប្រទេសវៀតណាម។ គម្រោងនេះបានឆ្លងកាត់ការដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិ ក្នុងគោលបំណងបង្កើតនូវភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដែលមានតម្លាភាព និងភាពប្រកួតប្រជែង និងផ្តល់នូវមូលដ្ឋាន សម្រាប់ប្រកួតប្រជែងដោយស្មើភាព។ ដូច្នេះ គម្រោងនេះនឹងបង្ហាញឲ្យឃើញពីប្រយោជន៍នៃធនធានថាមពលកកើតឡើងវិញ ដែលត្រូវបានប្រើប្រាស់មិនទាន់ដល់កម្រិតនៅឡើយ ក្នុងប្រទេសកម្ពុជា ហើយផ្តល់ជាគំរូដ៏សំខាន់ សម្រាប់វិស័យថាមពលកកើតឡើងវិញ ក្នុងប្រទេសនេះ។ សម្ព័ន្ធក្រុមហ៊ុន ដែលដឹកនាំដោយក្រុមហ៊ុន Sunseap ដែលជាក្រុមហ៊ុនអភិវឌ្ឍន៍ថាមពលពន្លឺព្រះអាទិត្យនាំមុខគេមកពីប្រទេសសឹង្ហបុរី បានឈ្នះការដេញថ្លៃនេះ ជាមួយនឹងការផ្តល់នូវតម្លៃសេវាប្រើប្រាស់ដែលមានភាពប្រកួតប្រជែងខ្ពស់ ពោលគឺទាបជាងថ្លៃអគ្គិសនី គិតជាមធ្យម ក្នុងប្រទេសកម្ពុជា។ |
| គោលដៅ និងទំហំ | គម្រោងនេះគឺជារោងចក្រផលិតថាមពលពន្លឺព្រះអាទិត្យសម្រាប់អតិថិជនទូទៅលើកទីមួយមិនធ្លាប់មាន ក្នុងប្រទេសកម្ពុជា និងជាគម្រោង IPP ខាងថាមពលកកើតឡើងវិញដែលបានឆ្លងកាត់ការប្រកួតប្រជែងដំបូងគេ ក្នុងប្រទេសនេះ។ តួនាទីនាំមុខរបស់ ADB ក្នុងកញ្ចប់ហិរញ្ញប្បទានសម្រាប់គម្រោងនេះ នឹងជួយបង្ហាញឲ្យឃើញពីអត្ថប្រយោជន៍នៃការបង្កើតការផ្គត់ផ្គង់ថាមពលនៅកម្ពុជា តាមរយៈការរៀបចំភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈដែលអស់ចំណាយទាប ដោយប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ។ គម្រោងនេះក៏បង្ហាញដល់រដ្ឋាភិបាល អ្នកវិនិយោគ និងអ្នកផ្តល់ហិរញ្ញប្បទានសាធារណៈផងដែរថា ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធដែលដឹកនាំដោយវិស័យឯកជន គឺជាការវិនិយោគដែលគេអាចធ្វើទៅបានប្រកបដោយតម្លាភាព ក្នុងតម្លៃប្រកួតប្រជែង ជាមួយនឹងកញ្ចប់ហិរញ្ញប្បទានដែលមានការរៀបចំបានល្អ។ |
| ការតភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រទេស/តំបន់ | គម្រោងនេះគឺស្របទៅតាមយុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេសរបស់ ADB ២០១៤-២០១៨ សម្រាប់ប្រទេសកម្ពុជា និងគោលនយោបាយថាមពលរបស់ ADB ។ |

## ប្រភេទនៃកិច្ចការពារ

| | |
|---|---|
| បរិស្ថាន | B |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | C |
| ជនជាតិដើមភាគតិច | C |

## សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម

| | |
|---|---|
| បរិស្ថាន | ការពិនិត្យបឋមលើបរិស្ថាន និងសង្គម (IESE) ត្រូវបានរៀបចំឡើង សម្រាប់គម្រោងនេះ។ គម្រោងនេះមានទីតាំងនៅឆ្ងាយពីតំបន់ដែលងាយរងផលប៉ះពាល់បរិស្ថាន និងភាគច្រើនហ៊ុមព័ទ្ធដោយវាលស្រែ។ ផលប៉ះពាល់ពាក់ព័ន្ធនឹងការងារសាងសង់ ដូចជា ការកើនឡើងនូវបរិមាណធូលី និងសម្លេងរំខាន ហានិភ័យសុខភាព និងសុវត្ថិភាពការងារ និងសហគមន៍ មិនត្រូវបានគេរំពឹងថានឹងមានក្នុងកម្រិតគួរឲ្យកត់សម្គាល់ឡើយ ដោយសារតែដំណាក់កាលសាងសង់មានរយៈពេលខ្លី និងដោយសារមានវិធានការកាត់បន្ថយផលប៉ះពាល់ដែលអាចអនុវត្តបាននៅគ្រប់ពេល។ |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | ដី ដែលត្រូវការសម្រាប់ទីតាំងគម្រោង ត្រូវបានទិញពីអ្នកលក់ តាមរយៈការចរចាដោយអ្នកទិញព្រមទិញ ហើយអ្នកលក់ព្រមលក់។ ខ្សែបញ្ជូនចរន្តអគ្គិសនីលើក្បាលដំឡើងលើប្រឡាយដែលមានស្រាប់ និងលើចំណីផ្លូវ ទៅតាមផែនការគ្រោងទុក ដើម្បីបញ្ចៀសផលប៉ះពាល់ផ្លាស់ប្តូរទីលំនៅប្រជាពលរដ្ឋដោយមិនស្ម័គ្រចិត្ត។ |
| ជនជាតិដើមភាគតិច | |

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

| | |
|---|---|
| កាលវិភាគសម្រាប់រៀបចំ ដំណើរការ អនុវត្តការរៀបចំការផ្តល់ជំនួយ | |
| **ការអនុម័តលើទស្សនទាន** | ២៦ កក្កដា ២០១៦ |
| **បេសកកម្មត្រួតពិនិត្យលម្អិត** | |
| **កិច្ចប្រជុំរបស់គណៈកម្មាធិការផ្តល់ឥណទាន** | ២៧ តុលា ២០១៦ |
| **ការអនុម័ត** | - |
| **បច្ចុប្បន្នភាព PDS លើកចុងក្រោយ** | ១៩ ធ្នូ ២០១៦ |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី មិនផ្តល់ការធានា ឬ ភាពជាតំណាងណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។